ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ១៩៥០ ព.ណ ៦៣៩

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រឡងប្រជែងជ្រើសរើសបេក្ខជនជាមន្ត្រីរាជការ សិស្ស និស្សិត ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងពាណិជ្ជកម្ម ឆ្នាំ២០១៦

ក្រសួងពាណិជ្ជកម្មសូមជម្រាបជូនដំណឹងដល់បេក្ខជន ជាមន្ត្រីរាជការ សិស្ស និស្សិត ឱ្យបានជ្រាបថា៖ ក្រសួងពាណិជ្ជកម្ម នឹងធ្វើការប្រឡងប្រជែងជ្រើសរើសបេក្ខជន ជាមន្ត្រីរាជការ សិស្ស និស្សិត ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងសម្រាប់ ឆ្នាំ២០១៦នេះ ចំនួន **៨៥កន្លែង** ក្នុងនោះមានប្រភេទក្របខណ្ឌ (**ក**) ចំនួន **៧៧កន្លែង** និងប្រភេទក្របខណ្ឌ (**ខ**) ចំនួន **០៨កន្លែង** ដើម្បីបំពេញការងារនៅតាមមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងនៅទីស្តីការក្រសួង ដូចមានខាងក្រោម៖

***ក-សម្រាប់ចូលបម្រើការងារនៅទីស្តីការក្រសួងចំនួន ៥១កន្លែង (ក្របខណ្ឌ «ក» ចំនួន ៤៧កន្លែង និង ក្របខណ្ឌ«ខ» ចំនួន ០៤កន្លែង រួមមាន៖***

| ល.រ | អង្គភាព | ចំនួនក្របខណ្ឌ | | |
|---|---|---|---|---|
| | | ក | ខ | សរុប |
| ១ | អគ្គាធិការដ្ឋាន | ២ | | ២ |
| ២ | អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | ៥ | ១ | ៦ |
| ៣ | អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ | ៩ | | ៩ |
| ៤ | អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស | ៩ | | ៩ |
| ៥ | អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម | ៥ | | ៥ |
| ៦ | អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម | ៥ | ២ | ៧ |
| ៧ | អគ្គនាយកដ្ឋានកាំកុងត្រូល | ១១ | | ១១ |
| ៨ | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | ១ | ១ | ២ |
| សរុប | | ៤៧ | ០៤ | ៥១ |

*១. មុខជំនាញដែលត្រូវជ្រើសរើសសម្រាប់ក្របខណ្ឌ«ក» ៤៧កន្លែង ចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ៖*

- ជំនាញគ្រប់គ្រងពាណិជ្ជកម្ម ចំនួន **១៥**កន្លែង
- ជំនាញគណនេយ្យ ធនាគារ និងហិរញ្ញវត្ថុ ចំនួន **០៦**កន្លែង
- ជំនាញច្បាប់ពាណិជ្ជកម្ម ចំនួន **០៥**កន្លែង
- ជំនាញច្បាប់អន្តរជាតិ ចំនួន **០៣**កន្លែង

- ជំនាញព័ត៌មានវិទ្យា ចំនួន ១០កន្លែង
- ជំនាញគីមី ចំនួន ០៨កន្លែង

*២. មុខជំនាញដែលត្រូវជ្រើសរើសសម្រាប់ក្របខណ្ឌ«ខ» ០៤កន្លែង កម្រិតបរិញ្ញាបត្ររង៖*

- ជំនាញគ្រប់គ្រងពាណិជ្ជកម្ម ចំនួន ០៤កន្លែង

**ខ-សម្រាប់ចូលបម្រើការងារនៅតាមមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្តចំនួន ៣៤កន្លែង ក្របខណ្ឌ «ក»ចំនួន ៣០កន្លែង និងក្របខណ្ឌ«ខ» ចំនួន ០៤កន្លែង ៖**

| ល.រ | អង្គភាព | ក្របខណ្ឌ ក | | ក្របខណ្ឌ ខ | |
|---|---|---|---|---|---|
| | | ចំនួនក្របខណ្ឌ | មុខជំនាញជ្រើសរើស | ចំនួនក្របខណ្ឌ | មុខជំនាញជ្រើសរើស |
| ១ | មន្ទីរព.ណ រាជធានី | ២<br>១<br>១ | គ្រប់គ្រងព.ណ<br>ព័ត៌មានវិទ្យា<br>ភាសាអង់គ្លេស | | |
| ២ | មន្ទីរព.ណ ខេត្តកណ្តាល | ១ | ព័ត៌មានវិទ្យា | | |
| ៣ | មន្ទីរព.ណ ខេត្តកំពង់ចាម | ១ | គណនេយ្យ | | |
| ៤ | មន្ទីរព.ណ ខេត្តត្បូងឃ្មុំ | ២ | គ្រប់គ្រងព.ណ<br>និងគណនេយ្យ | ១ | គ្រប់គ្រងព.ណ |
| ៥ | មន្ទីរព.ណ ខេត្តកំពង់ធំ | ១ | គ្រប់គ្រងព.ណ | ១ | គ្រប់គ្រងព.ណ |
| ៦ | មន្ទីរព.ណ ខេត្តពោធិសាត់ | ១ | គ្រប់គ្រងព.ណ | | |
| ៧ | មន្ទីរព.ណ ខេត្តកំពង់ឆ្នាំង | ១ | គ្រប់គ្រងព.ណ | | |
| ៨ | មន្ទីរព.ណ ខេត្តបាត់ដំបង | ១ | គ្រប់គ្រងព.ណ | | |
| ៩ | មន្ទីរព.ណ ខេត្តបន្ទាយមានជ័យ | ១ | គណនេយ្យ | | |
| ១០ | មន្ទីរព.ណ ខេត្តសៀមរាប | ២ | ធនាគារ ១<br>ព័ត៌មានវិទ្យា ១ | | |
| ១១ | មន្ទីរព.ណ ខេត្តកំពង់ស្ពឺ | ១ | គ្រប់គ្រងព.ណ | | |
| ១២ | មន្ទីរព.ណ ខេត្តកំពត | ១ | គណនេយ្យ | | |
| ១៣ | មន្ទីរព.ណ ខេត្តកែប | ១ | ព័ត៌មានវិទ្យា | | |
| ១៤ | មន្ទីរព.ណ ខេត្តតាកែវ | ១ | គណនេយ្យ | | |
| ១៥ | មន្ទីរព.ណ ខេត្តស្វាយរៀង | ២ | គ្រប់គ្រងព.ណ | | |
| ១៦ | មន្ទីរព.ណ ខេត្តព្រៃវែង | ១ | ច្បាប់ព.ណ | | |
| ១៧ | មន្ទីរព.ណ ខេត្តកោះកុង | ១ | គណនេយ្យ | | |
| ១៨ | មន្ទីរព.ណ ខេត្តព្រះសីហនុ | ១ | ធនាគារ | | |
| ១៩ | មន្ទីរព.ណ ខេត្តក្រចេះ | | | ១ | គ្រប់គ្រងព.ណ |
| ២០ | មន្ទីរព.ណ ខេត្តស្ទឹងត្រែង | ១ | គ្រប់គ្រងព.ណ | | |
| ២១ | មន្ទីរព.ណ ខេត្តព្រះវិហារ | ២ | សេដ្ឋកិច្ចព.ណ<br>និងព័ត៌មានវិទ្យា | | |
| ២២ | មន្ទីរព.ណ ខេត្តមណ្ឌលគិរី | ១ | គ្រប់គ្រងព.ណ | | |
| ២៣ | មន្ទីរព.ណ ខេត្តរតនគិរី | ១ | គ្រប់គ្រងព.ណ | | |
| ២៤ | មន្ទីរព.ណ ខេត្តឧត្តរមានជ័យ | | | ១ | គណនេយ្យ |
| ២៥ | មន្ទីរព.ណ ខេត្តប៉ៃលិន | ១ | គ្រប់គ្រងព.ណ | | |
| | សរុប | ៣០ | | ៤ | |

## គ- លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស៖

*បេក្ខជនទាំងពីរភេទត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖*

១- ត្រូវមានសញ្ជាតិខ្មែរ

២- បេក្ខជនទាំងអស់ ត្រូវមានចំណេះដឹងជាបឋមលើជំនាញកុំព្យូទ័រ (Microsoft Word& Excel) ឡើងទៅ ដែលមានវិញ្ញាបន បត្របញ្ជាក់ការសិក្សាត្រឹមត្រូវ

៣- **បេក្ខជនជាមន្ត្រីរាជការ ជនពិការ ស្ត្រី ជនជាតិភាគតិច និងអ្នកនៅតំបន់ដាច់ស្រយ៉ាល** ត្រូវបានផ្តល់អាទិភាព និងលើកទឹកចិត្ត

៤- **បេក្ខជនជាមន្ត្រីជាប់កិច្ចសន្យា** របស់ក្រសួងពាណិជ្ជកម្ម ដែលបានបម្រើការងារលើស ពី **៥ឆ្នាំ** ត្រូវបានផ្តល់អាទិភាព។

*<u>ក្របខណ្ឌ«ក»</u>*

១- ចំពោះបេក្ខជនជាមន្ត្រីរាជការ ដែលមានបំណងដាក់ពាក្យសុំចុះឈ្មោះប្រឡង ត្រូវបានបម្រើការងាររដ្ឋយ៉ាងតិច ៥ឆ្នាំ ដោយមានបញ្ជាក់វិញ្ញាបនប័ត្ររដ្ឋបាល និងលិខិតអនុញ្ញាតរបស់ប្រធានអង្គភាព/ស្ថាប័ន និងត្រូវមានអាយុមិនលើសពី ៤៥ឆ្នាំ (ឆ្នាំកំណើត១៩៧១)

២- ចំពោះបេក្ខជនជានិសិត្ស ពុំមែនជាព្រះសង្ឃ ដែលមានបំណងដាក់ពាក្យសុំចុះឈ្មោះប្រឡង គឺជាបេក្ខជនដែលមានសញ្ញាប័ត្រចាប់ពីបរិញ្ញាបត្រឡើងទៅ ឬសញ្ញាប័ត្រមានតម្លៃសមមូល និងត្រូវមានអាយុមិនលើសពី ៣០ឆ្នាំ (ឆ្នាំកំណើត១៩៨៦)

*<u>ក្របខណ្ឌ«ខ»</u>*

១- ចំពោះបេក្ខជនជាមន្ត្រីរាជការ ដែលមានបំណងដាក់ពាក្យសុំចុះឈ្មោះប្រឡង ត្រូវបានបម្រើការងាររដ្ឋយ៉ាងតិច ៥ឆ្នាំ ដោយមានបញ្ជាក់វិញ្ញាបនប័ត្ររដ្ឋបាល និងត្រូវមានអាយុមិនលើសពី ៤០ឆ្នាំ គិតត្រឹមថ្ងៃប្រឡង (ឆ្នាំកំណើត១៩៧៦)

២- ចំពោះបេក្ខជនជាសិស្ស និស្សិត ពុំមែនជាព្រះសង្ឃ ដែលមានបំណងដាក់ពាក្យសុំចុះឈ្មោះប្រឡង គឺជាបេក្ខជនដែលមានសញ្ញាប័ត្របរិញ្ញាបត្ររងឡើងទៅ ឬសញ្ញាប័ត្រមានតម្លៃសមមូល និងត្រូវមានអាយុមិនលើសពី ២៨ឆ្នាំ (ឆ្នាំកំណើត១៩៨៦)

## ឃ- កាលបរិច្ឆេទទទួលពាក្យ និងទីកន្លែងទទួលពាក្យសុំប្រឡង៖

- ការទទួលពាក្យសុំចុះឈ្មោះប្រឡងនឹងប្រព្រឹត្តទៅនៅរៀងរាល់ម៉ោងធ្វើការ ចាប់ផ្តើមពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី ***១៥ ខែកក្កដា ឆ្នាំ២០១៦*** ត្រឹមវេលាម៉ោង ១៧: ០០នាទី ជាកាលបរិច្ឆេទចុងក្រោយ
- បេក្ខជនត្រូវសរសេរ និងបំពេញសំណុំលិខិតសុំចុះឈ្មោះប្រឡង ត្រូវមកដាក់ពាក្យសុំចុះឈ្មោះប្រឡងប្រជែងដោយខ្លួនឯង នៅតាមទីកន្លែងកំណត់៖
  - *បេក្ខជនដែលដាក់ពាក្យសុំចុះឈ្មោះប្រឡងប្រជែង ចូលបម្រើការងារនៅតាមមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវដាក់ពាក្យនៅតាមមន្ទីរពាណិជ្ជកម្មរាជធានី ខេត្តនោះ*
  - *បេក្ខជនដែលដាក់ពាក្យសុំចុះឈ្មោះប្រឡងប្រជែង ចូលបម្រើការងារនៅទីស្តីការក្រសួង ត្រូវមកដាក់ពាក្យនៅលេខាធិការដ្ឋាន នៃគណៈកម្មការប្រឡងប្រជែងរបស់ក្រសួង (នាយកដ្ឋានបុគ្គលិក)*

- ការប្រឡងប្រជែងជ្រើសរើសបេក្ខជនជាមន្ត្រីរាជការ សិស្ស និសិត្ស ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងពាណិជ្ជកម្មសម្រាប់ ឆ្នាំ២០១៦នេះ ***ចាត់ទុកជាការប្រញាប់***។

## ខ- សំណុំលិខិតសុំចុះឈ្មោះប្រឡង៖

| | |
|---|---|
| ១- ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ច្បាប់ |
| ២- ជីវប្រវត្តិសង្ខេបមានបិទរូបថត( 4x6 ) (មានគំរូស្រាប់) | ចំនួន ០១ច្បាប់ |
| ៣- សលាកបត្រឯកត្តជន (មានគំរូស្រាប់) | ចំនួន ០២ច្បាប់ |
| ៤- បង្កាន់ដៃទទួលពាក្យ (មានគំរូស្រាប់) | ចំនួន ០២ច្បាប់ |
| ៥- លិខិតសន្យារបស់បេក្ខជនចូលបម្រើការងារ (មានគំរូស្រាប់) | ចំនួន ០១ច្បាប់ |
| ៦- ច្បាប់ចម្លងសញ្ញាប័ត្រជំនាញដោយមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ | ចំនួន ០១ច្បាប់ |
| ៧- ច្បាប់ចម្លងប័ណ្ណគ្រួសារ /សៀវភៅស្នាក់នៅ/ឬអត្តសញ្ញាណប័ណ្ណ ឬលិខិតបញ្ជាក់ទីលំនៅ | ចំនួន ០១ច្បាប់ |
| ៨- រូបថតថ្មី 4x6 (ថតចំពីមុខ) | ចំនួន ០២សន្លឹក |
| ៩- លិខិតថ្កោលទោសផ្តល់ជូនក្រោយពេលប្រឡងជាប់ រយៈពេល១ខែយ៉ាងយូរ | ចំនួន ០១ច្បាប់ |

## ច- វិញ្ញាសាប្រឡង៖

***សម្រាប់ការប្រឡងចូលប្រភេទក្របខណ្ឌ « ខ »***

| | | |
|---|---|---|
| ១- វិញ្ញាសាវប្បធម៌ទូទៅ | *មេគុណ ១* | *រយៈពេល ២ ម៉ោង* |
| ២- វិញ្ញាសាភាសាអង់គ្លេស | *មេគុណ ១* | *រយៈពេល ១ ម៉ោង និង ៣០ នាទី* |

***សម្រាប់ការប្រឡងចូលប្រភេទក្របខណ្ឌ « គ »***

| | | |
|---|---|---|
| ១- វិញ្ញាសាវប្បធម៌ទូទៅ | *មេគុណ ១* | *រយៈពេល ២ ម៉ោង* |
| ២- វិញ្ញាសាភាសាអង់គ្លេស | *មេគុណ ១* | *រយៈពេល ១ ម៉ោង និង ៣០ នាទី* |
| ៣- វិញ្ញាសាព័ត៌មានវិទ្យា | *មេគុណ ២* | *រយៈពេល ២ ម៉ោង* |
| ៤- វិញ្ញាទាក់ទងនឹងមុខជំនាញ | *មេគុណ ២* | *រយៈពេល ២ ម៉ោង* |

## ឆ- កាលបរិច្ឆេទ និងមណ្ឌលប្រឡង៖

១- **កាលបរិច្ឆេទប្រឡង៖ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៦**

***ពេលព្រឹក:*** ចាប់ពីម៉ោង ០៧: ៣០នាទី រហូតដល់ម៉ោង ១១: ៣០នាទី

***ពេលរសៀល:*** ចាប់ពីម៉ោង ១៤: ៣០នាទី រហូតដល់ម៉ោង ១៦: ៣០នាទី វិញ្ញាសាព័ត៌មានវិទ្យា និងវិញ្ញាសាទាក់ទងនឹងមុខជំនាញ

២- **មណ្ឌលប្រឡង៖** នឹងជូនដំណឹងនៅពេលប្រកាសបិទឈ្មោះបេក្ខជន នៅទីស្តីការក្រសួង(ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ)

***សូមបញ្ជាក់៖***

ព័ត៌មានលម្អិតផ្សេងៗទៀត បេក្ខជនអាចមកទំនាក់ទំនងដោយផ្ទាល់នៅលេខាធិការដ្ឋាននៃគណៈកម្មការរៀបចំការប្រឡងប្រជែង (នាយកដ្ឋានបុគ្គលិក) និងនៅតាមមន្ទីរពាណិជ្ជកម្មរាជធានី-

ខេត្ត រៀងរាល់ម៉ោងធ្វើការ ឬអាចពិនិត្យមើលនៅក្នុងគេហទំព័រ www.moc.gov.kh និង Facebook របស់ក្រសួងពាណិជ្ជកម្ម។

បេក្ខជនអាចទាញយកពាក្យស្នើសុំចុះឈ្មោះប្រឡងប្រជែងនេះតាមអាសយដ្ឋានខាងលើ ឬក៏អាចមកយកនៅលេខាធិការដ្ឋាននៃគណៈកម្មការប្រឡងប្រជែង ( នាយកដ្ឋានបុគ្គលិក ) នៅទីស្តីការក្រសួង (ចែកជូនដោយឥតគិតថ្លៃ)។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សុរស័ក្តិ**

<u>**ចម្លងជូន៖**</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ
- គ្រប់អគ្គនាយកដ្ឋាន អង្គភាព មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត
- គ្រឹះស្ថានសិក្សា
- ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន (ដើម្បីជួយផ្សព្វផ្សាយ)
- ឯកសារ-កាលប្បវត្តិ